# គោលនយោបាយបង់ថ្លៃសិក្សា

គោលបំណងនៃគោលនយោបាយនេះគឺដើម្បីបង្កើតនូវវិធីសាស្រ្តមួយដែលត្រឹមត្រូវ ឯកភាព និងតម្លាភាពចំពោះការទូទាត់ថ្លៃសិក្សា។ គោលនយោបាយនេះបង្កើតឡើងដើម្បីគាំទ្រដល់ទំនាក់ទំនងជាវិជ្ជមាន និងដោយក្តីគោរពរវាងមាតាបិតាសិស្ស និងសាលារៀនដោយធានាថាអ្នកទាំងអស់យល់យ៉ាងច្បាស់ពីការរំពឹងទុកគោលនយោបាយ និងនីតិវិធីនៃការទូទាត់ថ្លៃសិក្សានេះ។

ដោយសារជាស្ថាប័នពឹងផ្អែកលើថ្លៃសិក្សា សាលារៀនដើមឈើសិក្សាដំណើរការទៅបានអាស្រ័យលើការទទួលបានការទូទាត់ថ្លៃសិក្សាទាល់ពេលវេលា និងប្រកបដោយទំនុកចិត្តដើម្បីបន្តការផ្តល់នូវការអប់រំមួយប្រកបដោយគុណភាពខ្ពស់។ គោលនយោបាយនេះធានាថាគ្រប់ភាគីទាំងអស់បានដឹងច្បាស់ នៃដំណើរការដែលមានលក្ខណៈស្តង់ដាមួយ ដោយលើកកម្ពស់សមភាព និងគណនេយ្យភាពសម្រាប់គ្រប់ក្រុមគ្រួសារ។

## <u>ថ្លៃសិក្សាផ្អែកលើចំនួនថ្ងៃបង្រៀន២០៣ ថ្ងៃ និង៨ម៉ោងសិក្សាក្នុងមួយថ្ងៃ</u>

**កម្មវិធីសិក្សាពេញមួយថ្ងៃ ទារកដ្ឋានកម្រិត១ (អាយុ២ឆ្នាំ) ដល់ឆ្នាំទី៦ (អាយុ១១ឆ្នាំ)៖** ថ្លៃសិក្សា១៨០០ ដុល្លារ ក្នុងមួយឆ្នាំ។
**កម្មវិធីសិក្សាមួយពេល ទារកដ្ឋានកម្រិត១ និងទារកដ្ឋានកម្រិត២ ៖** ថ្លៃសិក្សា ៩៦០ ដុល្លារ ក្នុងមួយឆ្នាំ។

## <u>ជម្រើសក្នុងការទូទាត់ថ្លៃសិក្សា</u>

យើងខ្ញុំផ្តល់ជូនការបញ្ចុះតម្លៃសិក្សាជាច្រើនដើម្បីគាំទ្រដល់គ្រួសារទាំងឡាយ និងជំរុញឱ្យមានការប្តេជ្ញាក្នុងការចូលរួមរយៈពេលវែង។ តម្លៃសិក្សាត្រូវបង់ថ្លៃឱ្យបានគ្រប់មុនពេលចូលរៀនថ្ងៃដំបូង។ សិស្សានុសិស្សដែលមានសមតុល្យពុំទាន់បានទូទាត់នឹងមិនអនុញ្ញាតឱ្យចាប់ផ្តើមចូលរៀន ឬត្រឡប់មកសិក្សាបានទេរហូតទាល់តែសមតុល្យនោះត្រូវបានទូទាត់រួច។

## ការទូទាត់ថ្លៃសិក្សាប្រចាំឆ្នាំ - បញ្ចុះតម្លៃ១០%

- ការទូទាត់ត្រូវធ្វើឡើងត្រឹមថ្ងៃទី១៥ ខែសីហា ដើម្បីធានាថាសិស្សណាម្នាក់អាចចាប់ផ្តើមចូលរៀនទាន់ពេលវេលា។ (ប្រតិទិនសាលារៀននិងផ្តល់ជូនឱ្យបានច្បាស់លាស់)
- ថ្នាក់កុមារដ្ឋានកម្រិត១ ដល់ឆ្នាំទី៦ ពេញម៉ោងបញ្ចុះតម្លៃនៅសល់ត្រឹមតែ ១៦២០ ដុល្លារ
- ថ្នាក់កុមារដ្ឋានកម្រិត និងថ្នាក់កុមារដ្ឋានកម្រិត២ ក្រៅម៉ោងបញ្ចុះតម្លៃនៅសល់ត្រឹមតែ ៨៦៤ ដុល្លារ ។

## ការទូទាត់ថ្លៃសិក្សាតាមវគ្គសិក្សា -បញ្ចុះតម្លៃ៥%

- ការទូទាត់៣ដងត្រូវទូទាត់មុនពេលចាប់ផ្តើមវគ្គសិក្សានីមួយៗ។ (ថ្ងៃទី១៥ ខែសីហា, ថ្ងៃទី១៥ ខែធ្នូ និង ថ្ងៃទី១៥ ខែមីនា)
- ថ្នាក់កុមារដ្ឋានកម្រិត១ ដល់ឆ្នាំទី៦ ថ្នាក់ពេញម៉ោងបញ្ចុះតម្លៃនៅសល់ត្រឹមតែ ៥៧០ ដុល្លារក្នុងមួយវគ្គសិក្សា ។
- ថ្នាក់កុមារដ្ឋានកម្រិត១ និងថ្នាក់មូលដ្ឋានកម្រិត២បញ្ចុះតម្លៃនៅសល់ត្រឹមតែ ២៨៨ ដុល្លារក្នុងមួយវគ្គសិក្សា ។

## ការទូទាត់ថ្លៃសិក្សាប្រចាំខែ

- ការទូទាត់ថ្លៃសិក្សាប្រចាំខែត្រូវទូទាត់ឱ្យបានត្រឹមថ្ងៃទីមួយនៃខែប្រតិទិននីមួយៗ។

## ការបញ្ចុះតម្លៃសិក្សាសម្រាប់បងប្អូនបង្កើតច្រើន

- បញ្ចុះតម្លៃ៥% សម្រាប់រាល់កុមារទាំងអស់ដែលបានចុះឈ្មោះសិក្សាជាមួយ ឬបន្ទាប់ពីកុមារម្នាក់បានចុះឈ្មោះសិក្សាដំបូងរួច។

## ការបន្ថែមក្នុងតម្លៃសិក្សា

- តម្លៃសិក្សាសម្រាប់ចុះឈ្មោះចូលរៀន
- ថ្លៃមូលធនប្រចាំឆ្នាំ
- ឯកសណ្ឋាន២កំប្លេ

## តម្លៃសិក្សាបន្ថែម

ថ្លៃបន្ថែមលើឯកសណ្ឋាននីមួយៗ ១០ដុល្លារ

ថ្លៃអាហារថ្ងៃត្រង់១ដុល្លារក្នុងមួយថ្ងៃ

(ទូទាត់នៅចុងខែនីមួយៗ)

- អាហារសម្រន់ពេលព្រឹក បន្ទាប់ពីចប់កម្មវិធីក្លឹបសិក្សា
- សម្ភារៈសិក្សាទាំងអស់ និងធនធានផ្សេងៗ

## មធ្យោបាយទូទាត់ថ្លៃសិក្សា

- គ្រប់ថ្លៃទូទាត់ថ្លៃសិក្សាទាំងអស់ត្រូវទូទាត់ជាដុល្លារសហរដ្ឋអាមេរិក ($)
- ការទូទាត់ថ្លៃសិក្សាអាចទូទាត់ជាលុយសុទ្ធ ឬការផ្ទេរតាមអនឡាញដោយប្រើប្រាស់ព័ត៌មានលម្អិតដែលបានផ្តល់ជូននៅខាងក្រោម។

## លក្ខខណ្ឌក្នុងការទូទាត់ថ្លៃសិក្សា

1. ដើមឈើសិក្សាគឺប្តេជ្ញាយ៉ាងមុតមាំដើម្បីផ្តល់ជូននូវបរិស្ថានសិក្សាមួយប្រកបដោយសុវត្ថិភាព និងមានសន្តិសុខពេញលេញដល់សិស្សានុសិស្សទាំងអស់។ យើងខ្ញុំថែទាំរក្សានូវការធានារ៉ាប់រងទទួលខុសត្រូវជាសាធារណៈដើម្បីធានាដល់ការការពារក្នុងហេតុការណ៍ជាឧបទ្ទវហេតុដែលអាចនឹងកើតឡើងនៅបរិវេណសាលារៀនរបស់យើងខ្ញុំ។ លើសពីនោះទៅទៀត សមាជិកបុគ្គលិកទាំងអស់ទទួលបានការបណ្តុះបណ្តាលក្នុងជួយសង្គ្រោះបឋមដោយកាកបាទក្រហមកម្ពុជា បំពាក់បំប៉នពួកគេដើម្បីឆ្លើយតបដោយសមស្របក្នុងករណីមានគ្រោះអាសន្នបន្ទាន់ផ្នែកវេជ្ជសាស្ត្រកើតឡើង។ យើងខ្ញុំប្រកាន់ខ្ជាប់នូវភារកិច្ចក្នុងការថែទាំដ៏ម៉ត់ចត់ចំពោះរាល់កុមារទាំងអស់ក្នុងការថែទាំរបស់យើងខ្ញុំ និងចាត់វិធានការទទួលខុសត្រូវតាមជំហានដើម្បីរក្សាការពារដល់សុខុមាលភាពរាងកាយ និងផ្លូវចិត្តរបស់កុមារអំឡុងពេលម៉ោងសិក្សានៅសាលារៀន និងបរិវេណសាលារៀនរបស់យើងខ្ញុំ។
2. រាល់ការបង្រៀន និងថ្លៃសិក្សាទាំងអស់ដល់ពេលកំណត់ទៅតាមកាលបរិច្ឆេទដែលបានបញ្ជាក់ប្រាប់។ ការខកខានក្នុងការទូទាត់ថ្លៃសិក្សាក្នុងរយៈពេលបី(៣)សប្តាហ៍ កូនៗរបស់លោកអ្នកនឹងមិនអនុញ្ញាតឱ្យចូលសិក្សានៅក្នុងសាលាដើមឈើសិក្សាឡើយ។ ក្នុងករណីមានក្នុងបញ្ជីរងចាំចំណាត់ថ្នាក់ការសិក្សារបស់កូនៗលោកអ្នក ចំណាត់ថ្នាក់នោះនឹងផ្តល់ជូនដល់កុមារដំបូងក្នុងបញ្ជីនោះ។
3. សំណងថ្លៃសិក្សាដែលបានទូទាត់រួចនឹងត្រូវធ្វើឡើងដោយគិតទៅលើការស្នើសុំជាលាយលក្ខណ៍អក្សរ និងត្រូវអនុវត្តចំពោះតែថ្លៃសិក្សាពេញលេញ មិនមែនតាមវត្តមាន។ ពុំមានការសងថ្លៃសិក្សាជាចំណែកៗដែលត្រូវសងដល់សិស្សណាដែលបានឈប់រៀនអំឡុងពេលវគ្គសិក្សាឡើយ។

- ការសងថ្លៃសិក្សាអានអនុវត្តបានចំពោះសិស្សានុសិស្សណាដែលត្រូវបានដកចេញជាអចិន្ត្រៃយ៍ពីសាលាដើមឈើសិក្សា។ ប្រាក់សំណងនឹងមិនត្រូវប្រគល់ជូនចំពោះអវត្តមានបណ្តោះអាសន្នឡើយ ដូចជាការ

ឈប់សម្រាកលំហែកំសាន្ត ឬឈប់សម្រាកពេលផ្សេងអំឡុងពេលវគ្គសិក្សា ប្រសិនបើសិស្សានុសិស្សនៅតែបានចុះឈ្មោះចូលរៀន លើកលែងតែមានស្ថានភាពលើកលែងខ្លះៗ ដូចជាមានជម្ងឺរយៈពេលវែង ឬការផ្លាស់ទីលំនៅរបស់គ្រួសារទៅរស់នៅប្រទេសផ្សេង។

## ការបង្កើនថ្លៃសិក្សា

តម្លៃសិក្សាត្រូវបានពិនិត្យជាប្រចាំឆ្នាំអំឡុងពេលការអភិវឌ្ឍថវិកា និងជាកម្មវត្ថុនៃការប្រែប្រួល។ មាតាបិតានឹងទទួលបានការជូនដំណឹងយ៉ាងតិច២ខែមុនពេលចាប់ផ្តើមឆ្នាំសិក្សាថ្មី ប្រសិនបើមានការអនុវត្តការប្រែប្រួលតម្លៃសិក្សាណាមួយ។